ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

# មាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន១១នាក់ ពីប្រទេសម៉ាឡេស៊ី

------------

ស្ថានឯកអគ្គរាជទូត**កម្ពុជា**ប្រចាំប្រទេស**ម៉ាឡេស៊ី** បានរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**១១នាក់** ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. **អ៊ី.ស.ជ** | ភេទស្រី | អាយុ២២ឆ្នាំ | មកពីស្រុកឆ្លូង ខេត្តក្រចេះ |
| ២. **ធ.ប** | ភេទប្រុស | អាយុ១៧ឆ្នាំ | មកពីស្រុកបាទី ខេត្តតាកែវ |
| ៣. **រ.ម៉** | ភេទប្រុស | អាយុ៣០ឆ្នាំ | មកពីស្រុកដំបែរ ខេត្តត្បូងឃ្មុំ |
| ៤. **រ.ប.ស** | ភេទប្រុស | អាយុ២១ឆ្នាំ | មកពីស្រុកដំបែរ ខេត្តត្បូងឃ្មុំ |
| ៥. **ភ.ច** | ភេទប្រុស | អាយុ២៦ឆ្នាំ | មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| ៦. **ស.ស** | ភេទប្រុស | អាយុ៣១ឆ្នាំ | មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| ៧. **ផ.ស.វ** | ភេទប្រុស | អាយុ២៨ឆ្នាំ | មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| ៨. **គ.ល** | ភេទប្រុស | អាយុ២២ឆ្នាំ | មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| ៩. **ស.ច.ណ** | ភេទប្រុស | អាយុ២៧ឆ្នាំ | មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ |

ពលករ-ពលការិនីទាំង០៩នាក់ខាងលើ ត្រូវបានមិត្តភក្តិនាំទៅធ្វើការខុសច្បាប់នៅរោងចក្រប្លាស្ទិកក្នុងប្រទេសម៉ាឡេស៊ី កាលពីខែមិថុនា ឆ្នាំ២០១៦។ ដោយធ្វើការលំបាក ពួកគេបានទៅស្ថានទូតនៅថ្ងៃទី១៩ ខែធ្នូ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានសម្របសម្រួលដោះស្រាយជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី។

១០. ពលការិនីខ្មែរឈ្មោះ **ក.ស.រ** អាយុ៣០ឆ្នាំ មកពីស្រុកត្រាំកក់ ខេត្តតាកែវ បានទៅម៉ាឡេស៊ីធ្វើការងារផ្ទះ ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា ។ ដោយធ្វើការលំបាក

នាងបានទៅស្ថានទូតនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ នៅល្ងាចថ្ងៃទី២២ ខែធ្នូ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនី **ក.ស.រ** បានយល់ព្រមប្រគល់លិខិតឆ្លងដែន និងសំបុត្រយន្តហោះដល់នាង។

ពលករ-ពលការិនីចំនួន**១០នាក់** ខាងលើ បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃ**ទី២៣ ខែធ្នូ ឆ្នាំ២០១៦** វេលាម៉ោង **១៦:០០**នាទី តាមជើងយន្តហោះ AK534 ។

១១. ពលការិនី **រ.ស.រ** អាយុ២៨ឆ្នាំ មកពីខេត្តបាត់ដំបង បានទៅធ្វើការងារតាមផ្ទះក្នុងប្រទេសម៉ាឡេស៊ី ពីខែធ្នូ ឆ្នាំ២០០៩ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ កិច្ចសន្យាការងាររបស់ពលការិនី ត្រូវផុតកំណត់ក្នុងខែធ្នូ ឆ្នាំ២០១៦នេះ ហើយនាងមានបំណងវិលត្រឡប់មកកម្ពុជាវិញ។ តាមការស្នើសុំរបស់ស្ថានទូត និយោជកបានប្រគល់ជូនពលការិនីនូវប្រាក់ខែរបស់នាងទាំងអស់ចំនួន៩០០០ដុល្លារអាមេរិក លិខិតឆ្លងដែន និងសំបុត្រយន្តហោះ ។

ពលការិនី **រ.ស.រ** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី **២៤** ខែ **ធ្នូ** ឆ្នាំ **២០១៦** វេលាម៉ោង**១៧:៣០**នាទី តាមជើងយន្តហោះ MH762 ។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជា ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគជូនដល់ ពលករ-ពលការិនីទាំង**១១នាក់** ផងដែរ៕

ភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ